# ពពកនិងថ្ងៃ

*ពាក្យ៨*

*ពពកបាំងថ្ងៃៗបាំងពពក　　បាំងទៅបាំងមកផ្លាស់ពណ៌ផែនដី*
*ភិរុណបានចិត្តចាក់លិចលោកីយ　　រន្ទះធំថ្មីបាញ់បោះចោលលេង។*
*បាញ់រុក្ខជាតិញាតិមិនរអា　　បាញ់សត្វមនុស្សាសក្តាធំធេង*
*ញ័រកាយទទ្រាក់បាស់ដើងដួលគ្រេង　　ដឹងហេតុវង្វេងមិនស្តីមិនថា។*
*ពពកបាំងថ្ងៃៗបាំងពពក　　បាំងទៅបាំងមកចេញឫកអស្ចារ្យ*
*ឲ្យអ្នកផងឃើញពេញចក្រវាឡ៍　　ទោះអ្នកណាថាអញមិនខ្ចីព្យ។*
*ពពកបាំងថ្ងៃៗបាំងពពក　　បាំងទៅបាំងមកសត្វលោកព្រួយព្រី*
*ជូនក្តៅត្រជាក់ធ្លាក់កាយជាឈឺ　　សម្លេងផ្គុញព្យុស្តាប់ត្រចៀកឯង។*
*ពពកបាំងថ្ងៃៗបាំងពពក　　បាំងទៅបាំងមកដូចជាកំប្លែង*
*តែមានតួស្លាប់ខុសភាពជាក់ស្តែង　　ជាតិរឿងកំប្លែងជារឿងសំណើច។*
*ពពកបាំងថ្ងៃៗបាំងពពក　　បាំងទៅបាំងមកបញ្ចើបញ្ចើច*
*ទុក្ខកាន់តែធំសុខកាន់តែខើច　　លេងសើចៗឈាមដោកពសុធា។*
*ពពកបាំងថ្ងៃៗបាំងពពក　　បាំងទៅបាំងមកត្រូវដូចៗគ្នា*
*ដៃអា-កឯងមាត់ស្រែកជំទាល　　ថាគេលីលាអញជាអ្នកត្រូវ។*

*ភ្នំពេញ ២៣ វិច្ឆការ ២០០៦*
*សួយ ឡួយ*